# នឹកខ្មាសមនសិការ

## I have a guilty conscience

MEAS Suon

**មាស ស្ួន**

ដោយលោក មាស សួន មិនបានទុកអាសយដ្ឋានសំរាប់អោយក្រុមការងារយើងទាក់ទង ហើយលោកថែមទាំងមិនបានមកទទួលពានរង្វាន់ទៀតនោះ យើងក៏មិនអាចដឹងពីជីវប្រវត្តិសង្ខេបរបស់លោកបាន។

ចុងឆ្នាំ ១៩៩២ ខ្ញុំជាអ្នកកាសែតដ៏កំសត់ម្នាក់ ក្នុងចំណោមមិត្តភ័ក្រ្តអ្នកកាសែតជាច្រើនរូបរបស់ខ្ញុំ។ មិនមែនខ្ញុំខ្វះមុខរបរនឹងជ្រើសរើសនោះទេ តែខ្ញុំយល់ថា «មុខរបរជាអ្នកកាសែត ជាមុខរបរមានសេរីភាព»និងមានឱកាសជាច្រើន ក្នុងការប្រាស្រ័យទាក់ទងបានយ៉ាងទូលំទូលាយជាមួយជនានុជនគ្រប់បែបសណ្ឋាន ម្យ៉ាងទៀតរាល់ពេលជួបជាមួយសហសេវិករបស់ខ្ញុំគេទាំងឡាយតែងសំដែងនូវមោទនភាពចំពោះពាក្យស្លោកដែលព្យួរនៅតាមជញ្ជាំងកន្លែងធ្វើការ ÷ «អ្នកកាសែតប្តេជ្ញាចូលរួមយ៉ាងសកម្មក្នុងការកែប្រែសតិអារម្មណ៍ថ្មីក្នុងជីវភាពរស់នៅ»។ ប៉ុន្តែសព្វថ្ងៃនេះ អ្វីដែលថ្មី? អ្វីដែលចាស់? វាពិបាកនឹងបែងចែកឱ្យបានច្បាស់លាស់ណាស់ព្រោះសម័យកាលនេះ អ្វីៗវាហាក់ដូចជាវិលវក់អស់ហើយ។ ពីមនោគមវិជ្ជាមួយដែលដាក់ចុះពីលើ ហើយដែលមិនអាចប៉ះពាល់បាននោះ វាធ្វើឱ្យវិចវិលអស់នូវការផ្តើមគំនិត ការបង្កើតថ្មី ការរិះគិតបញ្ចេញទស្សនៈ និយាយដូច្នេះមិនមានន័យថាគេធ្វើការមិនកើតនោះទេ ក៏ប៉ុន្តែយើងចង់និយាយពីទស្សនវិស័យដែលមើលទៅអនាគត។ ឥឡូវមកដល់បរិយាកាសសង្គមមួយ ដែលមានភាពទទេរលីងស្រិលផ្ទែកមនោគមវិជ្ជា ដូច្នេះវាហាក់ដូចជាគេម្នាក់ៗមិនដឹងធ្វើដំណើរទៅតាមផ្លូវណា...និយមន័យពីតំលៃមនុស្សក៏ប្រែប្រួលអស់។

ជាមួយនឹងរថយន្តដ៏កញ្ចាស់ ជាមួយនឹងថ្មើរជើង និងរថយន្តឈ្នួលដ៏គួរឱ្យស្រងូតស្រងាត់ ជាមួយនឹងកាណូតនាវាដ៏គួរឱ្យអណ្តែតអណ្តូង ខ្ញុំបានចុះគ្រប់ច្រកល្ហកនៃជ្រុងមាតុភូមិ។ គឺប្រហែលមកពីបានដើរគ្រប់ទីកន្លែងនៃជនបទ ជួបប្រាស្រ័យជាច្រើនជាមួយកសិករ ជាមួយអ្នករងគ្រោះគ្រប់កលិយុគនៃពេលវេលា ជាមួយទឹកដីខ្មៅចខ្មាំឈើចាប់នេះហើយបានជាខ្ញុំហាក់ដូចជាមានកម្លាំងចិត្តដ៏អាថ៌កំបាំងក្នុងផ្លូវចិត្តមួយ អាចទប់ទល់បាននូវការរីកស្គុះស្គាយក្នុងបរិយាកាសសតិអារម្មណ៍ទីក្រុង។ ប៉ុន្តែ

ការទប់ទល់នេះ ជួនកាលក៏ត្រូវបានគេបកស្រាយថា «ជាអ្នកអន់ថយ ដើរមិនទាន់សភាពការណ៍ទៅវិញ»។ ជាការពិតណាស់មនុស្សយើងម្នាក់ៗអ្នកណាក៏ចង់បាន «ភាពសុខស្រួល» ក្នុងការរស់នៅដែរ ប៉ុន្តែទស្សនវិជ្ជាក្នុងការស្វែងរក «ភាពសុខស្រួល» នេះមានអត្ថន័យ និងផ្លូវបត់បែនខុសៗគ្នា។ មេកើយរបស់ខ្ញុំតែងនិយាយថា ៖

-ចុះមូលដ្ឋានតាមជនបទយករថយន្តចាស់ៗទៅបានហើយ។ រថយន្តថ្មីៗ ទុកក្នុងទីក្រុងដើម្បីសោភ័ណភាព។ នេះជាការសំរេចដ៏ «ងាយស្រួល» តែវាជាការគួរឱ្យធុញថប់របស់អ្នកអនុវត្តន៍។ មនុស្សយើងម្នាក់ៗ មិនត្រឹមតែចេះទទួលនូវវេទនារម្មណ៍ពីអ្នកដទៃប៉ុណ្ណោះទេ តែត្រូវចេះទទួលនូវវេទនារម្មណ៍នូវអ្វីៗដែលយើងបានប្រព្រឹត្តទៅលើគេឯងវិញផង។ ជាមួយនឹងការសំរេចដូចនេះ ខ្ញុំត្រូវដេកផ្លូវជាញឹកញាប់...។

ប៉ុន្មានឆ្នាំកន្លងទៅនេះ តាំងពីគេទាំងឡាយបានក្លាយទៅជា «មន្ត្រីកាសែត»មក គេទាំងឡាយហាក់ដូចជាមិនសូវបានយល់ដឹងច្បាស់ពីការជាក់ស្តែងនៅជនបទទេ។ ជាពិសេសគេទាំងឡាយបានក្លាយទៅជាមនុស្សទំយើខ្លួន ឆាប់ត្អូញត្អែរគ្រាន់តែមិនសូវស្រួលខ្លួនបន្តិច។ គេភ្លេចឈឹងថា «ដើម្បីឱ្យក្លាយទៅជាពលរដ្ឋម្នាក់ដ៏ប្រសើរ អាចទ្រទ្រង់អនាគតប្រទេសជាតិបាននោះ គេមិនត្រូវអាណិតខ្លួនឯងពេកនោះទេ»។

ជាមួយនឹងការរើរវាយដូច្នេះ ស្រាប់តែរថយន្តរពេញផ្លូវ។ «បែកកង់មួយទៀតហើយ!» អ្នកបើករថយន្តស្រែកលាន់មាត់ «យើងដេកផ្លូវទៀតហើយ!»។ យើងលោតចុះពីលើរថយន្តយ៉ាងអស់សង្ឃឹម។ លើផ្លូវដ៏ក្រលិកក្រលុកដែលដក់ភក់ដោយជុំៗ ទីនេះស្ងាត់ច្រៀប។ ផ្ទះអ្នកស្រុកដែលទើបនឹងសង់ នៅឆ្ងាយពីគ្នាមួយៗ ភាគច្រើនប្រក់ស្លឹក ហើយហាក់ដូចជាភូមិទើបនឹងរៀបចំថ្មីៗ។ ខ្ញុំដើរទៅស្ទាបកង់ឡានបំរុង ដែលមុននេះវាបែករួចទៅហើយ។ ពូបើកបរគាត់អង្គុយចោងហោងលើចិញ្ចើមផ្លូវ ស្ពោះទឹកមាត់ឈិតៗទាំងអារម្មណ៍មួហ្មង ព្រោះទីនេះនៅឆ្ងាយពីទីប្រជុំជន។ មិនដឹងគាត់មួម៉ៅជាមួយនឹងរថយន្តកញ្ចាស់ ឬមួម៉ៅនឹងតំបន់ដាច់ស្រយាលនេះ? រសៀលជ្រេបន្តិចទៅហើយ។ ខ្យល់រំភើយបក់ស្រាលៗលើសន្ទូងពណ៌បៃតងខ្ចី ផ្ទៃមេឃស្រឡះហាក់នៅឆ្ងាយសែនឆ្ងាយពិតជាវាលលំហ ដ៏ហេងហាងសំរាប់ខ្ញុំជាអ្នកកាសែត ដែលប្រដាប់ទៅដោយសំភារៈដ៏រយិរយាក។ មិនត្រឹមតែគ្មានការធានាច្បាស់លាស់ពីសំភារៈធ្វើការប៉ុណ្ណោះទេ តែត្រូវរងារក្នុងការធានាអំពីសិទ្ធិរបស់ខ្លួនទៅទៀត។ មានពេលខ្លះ មិត្តរួមវិជ្ជាជីវៈរបស់ខ្ញុំ ត្រូវញាក់សាច់ និងរត់គេចមិនត្រឹមតែរត់គេចពីគ្រាប់ «ខ្មាំងសត្រូវតាមបាញ់» ប៉ុណ្ណោះទេ តែ «គ្នាឯង» តាម «រករឿង» និង «គុំគួន» ព្រោះយើងមានពេលខ្លះបានសាកល្បងប្រើប្រាស់ចំណែកតូចមួយនៃពាក្យ «សេរីភាព និងប្រជា-

ធិបតេយ្យ»។ គិតឱ្យសព្វៗទៅ អ្នកណាក៏លើកជ្រោងពាក្យស្លោកនេះដែរ ប្រហែលសំរាប់តែខ្លួនគេម្នាក់ ឬសំរាប់តែក្រុមគេផ្ទាល់មុខហើយមើលទៅ ព្រោះគេយកអត្ថន័យនៃពាក្យនេះទៅបកស្រាយវែកញែករិះគន់អ្នកដទៃ ក្រុមដទៃបាន តែអ្នកដទៃ ក្រុមដទៃបកស្រាយចំពោះខ្លួនមិនបានទាល់តែសោះ។ ចំពោះភ្នែកមនុស្សលោកខាងលិច គេតែងកត់សំគាល់ថា «ប្រទេសកម្ពុជាកំពុងធ្វើដំណើរយឺតៗឆ្ពោះទៅកាន់ផ្លូវប្រជាធិបតេយ្យដ៏ទូលំទូលាយមួយ» ព្រោះគេសំគាល់ថា គណបក្សនយោបាយរាប់សិបកំពុងតែកកើតឡើង បើគិតតាំងពីប្រទេសកម្ពុជាឯករាជ្យពីអាណានិគមបារាំងមក។ ប៉ុន្តែចំពោះយើងដែលបានកកើត និងធំធាត់នៅលើទឹកដីដ៏សែនឈឺចាប់ និងគ្រោតគ្រាតនេះ សម្លឹងមើលទៅវាហាក់ដូចជាមានន័យថា «គេទាំងអស់គ្នា មិនអាចរួមរស់នៅជាមួយគ្នាបានតែម្តង» ក្រោយពីទឹកដីនេះបានឆ្លងកាត់នូវវាលពិឃាតយ៉ាងរង្គាល និងឃោរឃៅកន្លងមក។ ខ្ញុំបានសាកល្បងត្រិះរិះជាច្រើនសាអំពីមូលហេតុចំបងរបស់វា មូលហេតុយ៉ាងសាមញ្ញមួយបានលេចឡើង គឺគេទាំងអស់គ្នាមិនចេះទទួលស្គាល់ ឬមិនព្រមទទួលស្គាល់ស្នាដៃគ្នាទៅវិញទៅមក។ បើគេ «មិនព្រមស្គាល់ខ្លួនឯង និងមិនស្គាល់អ្នកដទៃ» គេប្រាកដជាមិនអាចរួមរស់ជាមួយអ្នកណាបានឡើយ។ គេទាំងឡាយមកពីគ្រប់ច្រកល្ហក មកពីបណ្តាប្រទេសសេរី មកពីបណ្តាប្រទេសប្រជា-ធិបតេយ្យ គេប្រហែលជាភ្លេចអំពីពេលវេលា «នៃការចេញដំណើរ» ជាថ្មីនៃមាតុភូមិរបស់ខ្លួនហើយ។ តាមមើលទៅ មានគណបក្សច្រើនពុំមែនជាលក្ខខណ្ឌតែមួយគត់ដែលធានានូវប្រជា-ធិបតេយ្យនោះទេ។ និយាយសែនសាមញ្ញដើម្បីងាយយល់សំរាប់យើងទាំងអស់គ្នា និងដើម្បីជាការចាប់ផ្តើមដំបូងនៅលើទឹកដីដែលមានសង្គ្រាមមិនចេះជិនណាយនេះ គឺថា «ស្គាល់គេ ស្គាល់ឯង ស្តាប់គេ ស្តាប់ឯង មើលគេ មើលឯង និងកុំចាត់ទុកថា អ្នកដែលមានទស្សនៈខុស ឬផ្ទុយពីខ្លួនថាជា «សត្រូវ» បានហើយ។ បើប្រើពាក្យសាមញ្ញនេះ គេធ្វើមិនបានផង តើមានប្រយោជន៍អ្វីនឹងលើកជ្រោងប្រជាធិបតេយ្យនេះឱ្យខ្ពស់កប់ពពកម្ល៉េះ។ ការមើលស្រាលគ្នាតាមមនោគតិ រវាង «អ្នកនៅ» និង «អ្នកចេញទៅហើយត្រឡប់មកវិញ» ក្រោយសង្គ្រាម បាននាំភាពអគតិគំនុំគុំគួនរបស់គេទៅដល់ការប្រមាថជនរួមជាតិខ្លួនឯង។ គេគួរតែយល់ថា «យើងចាប់ផ្តើមពីចំណុចណាមក ហើយចំណុចនេះ វាបន្សល់មកពីមរតកនៃអ្នកបង្កើតសង្គ្រាមអ្វីខ្លះនៅលើទឹកដីរបែករហែកប្រេះឆានេះ? »។

ប៉ុន្មានឆ្នាំកន្លងមកនេះ គឺជារយៈពេលដ៏សែនលំបាកវេទនា។ យើងដឹងហើយថាអ្វីៗគួរតែចាប់ផ្តើមឡើង ហើយគឺការចាប់ផ្តើមដោយសព្វមុខក្នុងជីវភាពរស់នៅ ដើម្បីធ្វើឱ្យគេទាំងឡាយនៅតែអាចរក្សាបានជំនឿមកលើការខិតខំរបស់យើង។

ប៉ុន្តែគេទាំងឡាយនៅតែមិនជឿថាយើង «លំបាកណាស់ និងគ្មានអ្វីក្នុងដៃទៀតផង» នាពេលមួយនៃការចាប់ផ្តើមកន្លងមក។

មានពេលមួយនោះ គេស្រែកដាស់តឿនឱ្យអ្នកកាសែតថា «ផ្លូវវៀចកុំបោះបង់»។ ឱ! បើម្នាក់ៗនាំគ្នាប្រកាន់យកសុភាសិតដែលបុព្វបុរសយើងបង្កើតឡើង កាលយើងរស់នៅក្រោមអាណានិគមបរទេសមកអនុវត្តក្នុងពេលយើងកំពុងដឹកនាំវាសនាយើងដោយខ្លួនយើង តើចរិយាធម៌សង្គមនឹងជាយ៉ាងណា? ខ្ញុំរវើរវាយ... ទទាំងទទើសក្នុងអារម្មណ៍ «អ្នកកាសែតជាយុទ្ធជនក្នុងគ្រប់សភាពការណ៍» ពាក្យប៉ុន្មានម៉ាត់នេះ ខ្ញុំខំស្រូបយកពេញណែនក្នុងបេះដូងក្នុងឆន្ទៈ ទីបំផុតសារជាតិសំរាប់ចិញ្ចឹមឆន្ទៈនេះវាងាប់កោសិកាអស់ទៅហើយ។ ឆន្ទៈដែលមានកម្លាំងខ្លាំងក្លាអាចពុះពារបញ្ហាអ្វីៗបាននោះ លុះត្រាតែឆន្ទៈនោះមានគោលបំណងច្បាស់លាស់ បើមិនដូច្នោះទេ វាគ្រាន់តែជាកម្លាំងរំភើបមួយភ្លែតតែប៉ុណ្ណោះ។

ខ្ញុំស្លុងក្នុងភាពតប់ប្រមល់ ភ្លេចគិតថា «ដេកផ្លូវ» ហើយកំពុងឈរក្នុងវាលខ្យល់ដ៏បរិសុទ្ធ។ ខ្ញុំខំប្រមូលភាពច្របូកច្របល់នេះមកវិញ។ ថ្ងៃជិតលិចទៅហើយ ជះពណ៌ក្រហមឆ្អិនឆ្អៅនៅពីក្រោយផ្ទាំងពពកពណ៌ប្រផេះមួយចំហៀងមេឃឯនាយឆ្ងាយសន្ធឹម ឆ្ងាយពីក្តីសង្ឃឹមរបស់ខ្ញុំ...។
មនុស្សម្នាក់មកឈរពីក្រោយខ្នងខ្ញុំពីអង្កាល់ ខ្ញុំមិនចាប់ភ្លឹកសោះ។ ខ្ញុំងាកក្រោយជាមួយនឹងសម្លេងឧទានរបស់គេទាំងត្រេកអរ «បង! បង! »។ គឺខ្ញុំទេដែលជាអ្នកត្រេកអរហួសប្រមាណ ព្រោះបានជួបអ្នកដែលយើងធ្លាប់ស្គាល់។ ស៊ីផាន់! ឈ្មោះពីរម៉ាត់នេះជិតជាប់ក្នុងអារម្មណ៍របស់ខ្ញុំ។ នាយជាយុទ្ធជនពិការម្នាក់ ដែលត្រូវរបួសជាមួយនឹងជ័យជំនះនារដូវប្រាំងនៅឯសមរភូមិព្រំដែនកម្ពុជា-ថៃ។ យើងបានស្គាល់គ្នាដោយចៃដន្យ...។

កាលនោះស៊ីផាន់ត្រូវរបួសជើងទាំងពីរ ហើយបានមកសំរាកព្យាបាលរបួសនៅឯមន្ទីរពេទ្យធំក្រុងភ្នំពេញ។ ពេលល្ងាចថ្ងៃមួយនោះ ភ្លៀងធ្លាក់ដូចចាក់ទឹក។ ស៊ីផាន់ នៅសល់ជើងតែម្ខាងទេ។ នាយអង្គុយក្បែរមាត់បង្អួច សម្លឹងមើលទឹកភ្លៀងយ៉ាងស្លុតក្នុងអារម្មណ៍។ ខ្ញុំលួចសម្លឹងមើលនាយទាំងក្តុកក្តួលក្នុងចិត្ត។ អារម្មណ៍របស់នាយ ហាក់អណ្តែតរសាត់កាត់សរសៃទឹកភ្លៀងទៅរកអតីតកាល ទៅរករឿងរ៉ាវជាច្រើនដែលកន្លងផុតទៅហើយ។ គឺជាការកន្លងផុតក្នុងជីវិត ពោរពេញដោយការរីករាយ និងលំបាកលំបិន។ ខ្សែភ្នែករបស់នាយហាក់មើលទៅឆ្ងាយ ឆ្ងាយចំពោះអនាគតដ៏មិនច្បាស់លាស់ ដែលកំពុងរង់ចាំនាយ។ ស៊ីផាន់ និយាយតិចៗហាក់ដូចត្អូញត្អែរសំរាប់ខ្លួនឯងថា÷
-ភ្លៀងខ្លាំងម្លឹងៗមិត្តរួមអាវុធខ្ញុំទទឹកអស់ហើយ។ គេម្នាក់ៗមិនទាន់មានក្រណាត់កៅស៊ូគ្រប់គ្នាផង។ នាយនិយាយមិនដឹងសំដៅរកអ្នកណា បើក្នុងបន្ទប់នេះមានខ្ញុំ និងភរិយាព្រមទាំងកូនពីរនាក់

របស់នាយដែលអង្គុយផ្អែកខ្នងនឹងជញ្ជាំងនៅក្បែរនាង។ នាងសម្លឹងមុខប្ដីទាំងសញ្ជប់សញ្ជឹង។ មិនដឹងជាយ៉ាងម៉េចបានជាសំដីប៉ុន្មានឃ្លានេះហាក់ដូចជាមានអំណាចចិត្តជំរុញអោយខ្ញុំព្រឺព្រួច និងទទួលអារម្មណ៍ឈាមរត់ត្រសីបពេញរាងកាយ។ ទឹកចិត្តដ៏ខ្ពង់ខ្ពស់របស់ស៊ីផាន់ ធ្វើឱ្យខ្ញុំខ្មាសអៀននឹងខ្លួនឯង។ នាយបន្តដោយបែរមកសម្លឹងខ្ញុំក្នុងរង្វង់កែវភ្នែកដិតទៅដោយភាពស្លូតបូត នឹងន តែត្រម៉ង់ត្រមោច ÷

-តាមសមរភូមិ យើងទាំងអស់គ្នារស់នៅដូចគ្រួសារតែមួយ។ ជាច្រើនឆ្នាំកន្លងមក សុខទុក្ខរួមគ្នា អត់ឃ្លានរួមគ្នាមិនដែលមានសោះនូវពន្លកគំនិតរង្កៀសចិត្តនឹងគ្នា។ ភាពស្រលាញ់រាប់អានគ្នាក្នុងកងអង្គភាពវាហាក់បង្គ្រប់នូវអ្វីៗដែលព្រាត់ប្រាស់ ខ្វះខាតដែលនៅទីនោះតែងជួបជាប្រចាំ។

ស៊ីផាន់ដើរមកអង្គុយលើគ្រែរួចបន្ត ÷

-ផ្នត់គំនិតអ្នកទីក្រុងខុសពីអ្វីៗដែលខ្ញុំធ្លាប់ជួបប្រទះ។ ខ្ញុំសំរាកនៅទីនេះមិនបារម្ភពីគ្រាប់កាំភ្លើង តែខ្ញុំទទួលអារម្មណ៍ថា «ហាក់ដូចឯកោណាស់»។

អារម្មណ៍របស់ខ្ញុំប្រែទៅជាធ្ងាំងច្របូកច្របល់ ហើយសំដីគ្រប់ម៉ាត់នេះដូចជានៅវិលវល់ពេញបន្ទប់បោកផ្ទប់ទៅនឹងជញ្ជាំងពណ៌ស លាយឡំជាមួយសរសៃទឹកភ្លៀងធ្លាក់ល្អិតបោកមកលើបង្អួចកញ្ចក់ស្រាលៗ បុកលើទ្រូងខ្ញុំឱ្យថប់ដង្ហើមស្ទុះស្ទាប់ដោយមិនដឹងថា ស៊ីផាន់ឈប់និយាយពីអង្កាល់ផង។ នៅខាងក្រៅ សន្ធិប្រកាសបានគ្របដណ្ដប់បន្តិចម្ដងៗ។ សរសៃទឹកភ្លៀងចាំងទៅនឹងអំពូលអគ្គីសនីក្នុងទីធ្លាមន្ទីរពេទ្យប្រៀបដូចសរសៃប្រាក់ ដែលរោយពីលើមេឃ។

ជាច្រើនសប្ដាហ៍កន្លងមក ស៊ីផាន់ព្រមទាំងគ្រួសារបានចាកចេញពីមន្ទីរពេទ្យ។ ដៃកាន់ឈើច្រត់កូនតូចៗរបស់គេអៀវកឪពុក ភរិយារបស់គេដៃម្ខាងដឹកដៃកូន ដៃម្ខាងកាន់បង្វិចចុះតាមក្រោយប្ដី។ ទឹកមុខរីករាយស្រស់ត្រកាល។ គឺជាទឹកមុខភរិយាម្នាក់ដែលបានរស់នៅជិតប្ដីដែលខ្លួនស្រឡាញ់កក់ក្ដៅ ក្រោយពីស្រមោលអពមង្គលទាំងឡាយបានកន្លងផុតអស់ទៅហើយ។ នាងច្រៀងរហ៊ឹមៗម្នាក់ឯងចុះជណ្ដើរបណ្ដើរ។ ខ្ញុំសម្លឹងពីក្រោយដោយរអាក់រអួលក្នុងចិត្ត។ ខ្ញុំគិតថា «នាងប្រហែលសប្បាយមួយភ្លែត ដោយប្ដីបានជាសះស្បើយ ប៉ុន្តែអ្វីដែលនឹងកើតឡើងក្នុងការរស់នៅនឹងធ្វើឱ្យនាងតានតឹងផ្លូវចិត្តជាមិនខាន»។ នាងតែងនិយាយជាមួយខ្ញុំជាញឹកញាប់ថា ÷ «ខ្ញុំចង់ទៅរស់នៅក្នុងស្រុកភូមិ ទោះជាជួបការលំបាកយ៉ាងណាក៏ដោយ ឱ្យតែបានរស់នៅជិតប្ដី។ គាត់ពិការទៅហើយ គាត់ត្រូវការខ្ញុំជាងពេលមុនៗទៅទៀត»។ ក្នុងអារម្មណ៍របស់នាង ហាក់ដិតដាមទៅដោយភាពភ័យរន្ធត់ស្រយុតចិត្ត ក្រោយពេលដឹងថាប្ដីនាងមានរបួសក្នុងសង្គ្រាម។ ប្រហែលជាការស្លុតចិត្តរបស់ភរិយាទូទៅដែលមានចំពោះប្ដីធ្វើជាទាហាន។ នាងនៅតែភ័យខ្លាចដូចស្រមោលអន្ទោល

តាមប្រាណ ហើយអារម្មណ៍ជ្រួលច្របល់នេះតែងស្ថិតជាប់នៅក្នុងព្រលឹងរបស់នាង។ នាងតែងសម្លឹងមើលមុខប្តី មើលមុខរបួសដែលពោររលួយ។ នាងតែងនិយាយជារឿយៗ «មិនឱ្យបងទៅឆ្ងាយទៀតទេ»។ ស៊ីផាន់ តែងអង្អែលសក់ក្បាលភរិយាដោយថ្នមៗ ដកដង្ហើមធំ ភ្នែកសំលឹងមើលកង្ហារនៅលើពិដានដែលវិលដដែលៗ ហាក់បង្វិលយកក្តីសង្ឃឹមរបស់គេឱ្យវិលវល់នៅក្នុងការគិតគូរជីវិតសាជាថ្មី ក្រោយពេលជាសះស្បើយ។ នេះជាសេចក្តីស្នេហាសែនសាមញ្ញ តែមានលក្ខណៈសំបូរបែបដែលគេទាំងពីរនាក់បានដឹកនាំដោយមោទនភាពសំរាប់ខ្លួនគេ។ ខ្ញុំហុចដៃទទួលយកកូនពីកស៊ីផាន់ ពេលអ្នកទាំងពីរចុះដល់ក្រោម។

-តស់! ស៊ីផាន់ទៅសំរាកផ្ទះខ្ញុំសិន។

-បាទ! អរគុណបងណាស់។ នាយឆ្លើយយ៉ាងរួញរា រួចទីបំផុតក៏ងក់ក្បាលយល់ព្រម។

ក្រោយពីនោះមក យើងក៏បែកគ្នារហូតមក...។

មេឃងងឹតណាស់ទៅហើយ។ ស្នូរស្លឹកសន្ទូងដែលទើបនឹងប្តូរពណ៌នៅតែលាន់ស្រាវៗជាមួយនឹងជំនោររំភើយៗ។ ស៊ីផាន់ មិនអាចលាក់លៀមបាននូវការរីករាយរបស់នាយ ពេលបានជួបអ្នកដែលនាយហាក់ដូចចងចាំជានិច្ច។ នាយរៀបរាប់ហូរហែពីជីវភាពអ្នកស្រុកនៅម្តុំនេះ រៀបរាប់ដោយត្រេកត្រអាល ប៉ុន្តែចំពោះខ្លួននាយផ្ទាល់ តាំងពីដើមផ្លូវចូលដល់ផ្ទះនាយៗមិនរំលឹកដល់ទាល់តែសោះ។ យើងទាំងពីរនាក់រៀបរាប់ពីពេលវេលាមួយដែលហាក់ដូចជាកន្លងទៅយូរបំផុត តែមានសភាពដូចអ្វីៗនៅថ្មីស្រឡាង។ ប្រហែលមកពីការនឹករលឹកគ្នា និងការស្រលាញ់រាប់អានគ្នានេះហើយដែលធ្វើឱ្យអ្វីៗនៅតែស្រស់ត្រកាលក្នុងសន្តានចិត្តរបស់យើង។

-ដល់ផ្ទះខ្ញុំហើយបង!

ល្ងាចនោះ ពួកយើងហូបបាយយ៉ាងរីករាយ។ ម្ហូបសាមញ្ញបំផុត តែដូចជាកក់ក្តៅ និងត្រអាលបំផុត។ ក្នុងផ្ទះដ៏តូចច្រឡឹងនេះ គ្មានសំភារៈអ្វីដែលទំនើបនោះទេ ប៉ុន្តែការរៀបចំមានរបៀបរៀបរយ។ អ្វីដែលទាក់ទាញភ្នែករបស់ខ្ញុំ គឺក្តារខៀនមួយ តុកៅអី និងសៀវភៅមួយចំនួននៅលើតុ។

-ខ្ញុំមើលទៅផាន់ឯងដូចនៅរឹងប៉ឹងណាស់។

-ការលំបាកលំបិន បានធ្វើឱ្យគ្រួសារខ្ញុំកាន់តែរឹងប៉ឹងជាងមុន។ ភរិយាស៊ីផាន់ ឆ្លើយចេញពីចង្ក្រានមក។

-រស់នៅដូច្នេះដូចជាមានឧបសគ្គច្រើនណាស់។ ខ្ញុំផ្តើមនិយាយ។ ម៉េចបានជាផាន់មិនទៅរស់នៅក្នុងមជ្ឈមណ្ឌលប្រមូលផ្តុំ? ខ្ញុំដឹងថាកន្លែងនោះគេយកចិត្តទុកដាក់ទំនុកបំរុងជាច្រើន។ ខ្ញុំមិនទាន់បញ្ចប់ឃ្លារបស់ខ្ញុំផង ស្រាប់តែបាយដែលដាក់ក្នុងមាត់រៀបទំពាលេបទៅហើយ មិនដឹងយ៉ាងម៉េច

ពេលនោះស្រាប់តែស៊ីផាន់ ចង់ក្អួតខ្ទាក់មកវិញធ្វើឱ្យដាច់ប្រយោគរបស់ខ្ញុំ។ នាយមិនឆ្លើយនឹងសំណួរនេះទេ បែរជាងាកមុខសម្លឹងមើលទៅមាត់បង្អួចស្លុងទៅរកភាពងងឹតយ៉ាងជ្រៅត្រលួងនៅឯក្រៅផ្ទះ។ នាយសើចស្ងួតហើយបែរជាសួរមកកាន់ខ្ញុំរឿងផ្សេងទៅវិញ ÷

-បងដឹងទេ តើខ្ញុំធ្វើយ៉ាងម៉េចខ្លះដើម្បីកុំឱ្យធុញទ្រាន់ និងស្អប់ខ្ពើមនឹងខ្លួនឯង? ខ្ញុំស្លឹក្នុងគំនិត មិនទាន់បានរៀបចំចម្លើយស្រួលបួលផង ស៊ីផាន់បន្ត ÷

-ក្រោយពេលការងារប្រចាំថ្ងៃ ខ្ញុំតែងរំលឹកឡើងវិញនូវអំពើល្អជាច្រើន ដែលខ្ញុំបានធ្វើកន្លងមក។ ខ្ញុំយល់ថា មនុស្សយើងម្នាក់ៗបើព្យាយាមរំលឹកអំពីអំពើល្អៗដែលយើងបានធ្វើចំពោះអ្នកដទៃ គេនឹងពេញចិត្តនឹងខ្លួនឯងហើយគេយល់ថា ជីវិតគេនៅតែស្រស់បំព្រងជាមិនខាន។ ខ្ញុំក៏ដូច្នេះដែរ។ អ្នកណាមិនសរសើរខ្ញុំក៏ហីទៅចុះ តែខ្ញុំពេញចិត្តនឹងខ្លួនឯង ព្រោះខ្ញុំមិនដែលបានរំខានអ្វីដល់អ្នកដទៃ ដែលនាំឱ្យស្តាយក្រោយនោះទេ។ ខ្ញុំបានបូជាជើងម្ខាងដើម្បីមាតុភូមិ ខ្ញុំមិនត្រូវការអ្វីសំរាប់ខ្ញុំទេ។ ខ្ញុំត្រូវការតែម៉្យាង គឺអនាគតកូនរបស់ខ្ញុំ។ នៅទីនេះខ្ញុំបានអប់រំកូនរបស់ខ្ញុំដោយផ្ទាល់ដៃ។ ខ្ញុំបានបង្រៀនកូនរបស់ខ្ញុំនៅផ្ទះក្រោយពួកវាចេញពីសាលា។ មានការងារជាច្រើនដែលត្រូវធ្វើនៅជនបទនេះ ដូច្នេះនាំឱ្យខ្ញុំភ្លេចថាខ្ញុំពិការ។ ខ្ញុំបានរស់នៅដូចគេឯង។ ខ្ញុំបានប្រកបការងារសាមញ្ញដូចគេឯងនៅតាមជនបទ។ ជនបទស្រុកយើងមានលក្ខណៈសាមញ្ញណាស់ តែមានលក្ខណៈសំបូរបែបម៉្យាងដែលគេមិនអាចបំភ្លេចដោយងាយៗបានដែរ។ គ្រាន់តែក្លិនចំហាយដីនៅដើមរដូវភ្លៀងធ្លាក់ ក៏ធ្វើឱ្យយើងទទួលអារម្មណ៍ម៉្យាងភ្លឺស្វាងក្នុងខួរក្បាលដែរ។

ខ្ញុំស្តាប់ស៊ីផាន់ រៀបរាប់ភ្លេចហូបបាយ។ ខ្ញុំគិតថា ស៊ីផាន់បានចំណាយពេលវេលាជាច្រើនដើម្បីអានសៀវភៅ និងពិចារណាបញ្ហាជាច្រើនក្នុងជីវិតរបស់នាយ ទើបនិយាយបានហូរហែយ៉ាងនេះ។

ស៊ីផាន់បន្ត ÷

-ឥឡូវខ្ញុំកាន់តែយល់ច្បាស់នូវពាក្យមួយឃ្លាដែលគេនិយាយថា «មានវត្ថុបីយ៉ាងជារង្វាន់សំរាប់យើង គឺរបៀបដឹកនាំបញ្ញា រយៈពេលសំបូរសប្បាយដោយធនធាន និងរយៈពេលជួបអពមង្គល»។ ខ្ញុំហាក់ចម្លែកដូចជាមានជំនក់ចិត្តស្តាប់ស៊ីផាន់ មិនធុញទ្រាន់ ហើយប្រសើរជាងបានអង្គុយស្តាប់មនុស្សមួយចំនួននៅទីក្រុងដែលគេនិយាយអោយយើងស្តាប់ ហើយគេខំកៀងគរឱ្យយើងទៅស្តាប់ ដោយខានមិនបានទៀតផង។

-បងដឹងទេ ឥឡូវនេះកូនរបស់ខ្ញុំវាហាក់ដូចជាកាន់តែត្រូវការ និងស្រឡាញ់ឪពុកកាន់តែខ្លាំងឡើងៗហើយ។ ភរិយាស៊ីផាន់ និយាយសួរមកកាន់ខ្ញុំ ក្រោយនាងលើកម្ហូបមកដល់។

ខ្ញុំទទួលចានម្ហូបពីដៃនាង ហើយនិយាយថា «នោះប្រាកដជាដោយសារពួកវាកាន់តែធំ ហើយ

ឃើញថាឪពុកម្តាយខិតខំជំនះគ្រប់យ៉ាងដើម្បីពួកវាហើយ។ មានឪពុកម្តាយខ្លះ បានយកក្រឹត្យក្រមធម្មជាតិនេះមកដាក់ទំងន់លើជីវិតរបស់កូនដោយចាត់ទុកថា នេះជាគុណបំណាច់ដែលត្រូវសងមកវិញ ដោយខានមិនបានជាដាច់ខាត»។

-ខ្ញុំមិនគិតដូច្នេះទេ។ ស៊ីផាន់ឆ្លើយកាត់ឡើង។ ខ្ញុំគ្រាន់តែខិតខំគ្រប់យ៉ាងឱ្យពួកវាយល់ និងទទួលដោយស្មោះថា នេះជាអំពើរបស់មនុស្សដែលគិតគូរ និងស្រឡាញ់វាតែប៉ុណ្ណោះ។ បើនិយាយតាមបែបជឿនលឿនបន្តិចនោះ យើងមិនត្រូវរំលឹកដដែលៗចំពោះមុខកូនថា នេះជាគុណបំណាច់ដែលត្រូវមានបំណុលនោះទេ។

ស៊ីផាន់យកដៃអង្អែលក្បាលកូនដោយញញឹម។

យប់នោះក្រោយពេលបាយល្ងាចរួច យើងបានសំណេះសំណាលគ្នាមិនចេះអស់រឿង។ នៅខាងក្រៅ មេឃងងឹតចាក់ភ្នែកមិនយល់។ នៅឯនាយ ចង្កៀងភ្លឺព្រឹមៗតាមផ្ទះស្លឹកដែលដាច់គ្នាពីមួយទៅមួយ មើលទៅហាក់ដូចជាតំបន់មួយដែលគ្មានជីវិត។ យូរៗម្តង ឆ្កែលូល្វើយៗយ៉ាងគ្រលួចអណ្តែតអណ្តូង ផ្កាយរះព្រោងព្រាត...។

-បងឃើញទេ ជនបទយើង ពីកាលណាមកនៅតែប៉ុណ្ណឹង គ្មានស៊ីផ្លាស់ប្តូរទេ។ ស៊ីផាន់ និយាយមកកាន់ខ្ញុំ ព្រមទាំងចង្អុលទៅវាលល្វឹងល្វើយងងឹតសូន្យសុង នាយបន្តទៀតថា ÷

-ខ្ញុំបានមើលកម្មវិធីនយោបាយគ្រប់គណបក្សនយោបាយ គេតែងលើកឡើងថា «ប្រទេសខ្មែរយើងជាប្រទេសកសិកម្ម ហើយជាកសិកម្មអន់ថយទៅទៀត...» ប៉ុន្តែខ្ញុំមិនប្រទះឃើញវគ្គត្រង់ណា ដែលគេគូសវាសជាក់ស្តែងដើម្បីអភិវឌ្ឍជនបទសោះ។ ជនបទមិនទាមទារអ្វីច្រើនទេ។ ជាធម្មតា ទីក្រុងសំបូរដោយបទចំរៀងព្រោះគេសំបូរភ្លើងពណ៌ កន្លែងរាំរែក ឯជនបទសំបូរដោយចំរៀងបាន លុះត្រាណាតែកសិករមានបាយហូបគ្រប់គ្រាន់ និងស្រូវបំរុងនៅពេញក្នុងជង្រុក។

ព្រលឹមស្រាងៗ ខ្ញុំបានលាគ្រួសារស៊ីផាន់ទាំងអាឡោះអាល័យ។ ស៊ីផាន់បានជូនដំណើរខ្ញុំមកដល់មាត់ផ្លូវ។ ខ្ញុំសម្លឹងទៅក្រោយ ឃើញស៊ីផាន់កាន់ដៃកូនៗទប់ខ្លួននឹងឈើច្រត់ ឈរសម្លឹងមើលមកខ្ញុំ រហូតដាច់កន្ទុយភ្នែក។ មនុស្សពិការម្នាក់នេះ គួរតែត្រូវបានគេជួយផ្តល់កម្លាំងចិត្តដល់គេទើបសមរម្យ «ខ្ញុំនឹងក្នុងចិត្ត» ព្រោះគេបានឈរយ៉ាងជ្រងោ រឹងមាំចំពោះពិការភាពរបស់គេ ហើយសន្តានចិត្តរបស់នាយនៅតែស្ងប់ស្ងាត់ គ្មានប្រៀបធៀប គ្មានការច្រណែន នឹងនរគួរស្ងប់ស្ងែង។ ខ្ញុំអៀនខ្មាសនឹងខ្លួនឯង ហើយកាន់តែធុញថប់នឹងមនុស្សទំនើបនៅទីក្រុង។ ខ្ញុំបានមកដល់ទីរួមខេត្ត ដោយពុំមានផលរមាស់អ្វីគួរអោយកត់សំគាល់។ ខ្ញុំបានជួបជជែកលេងជាមួយអ្នករកស៊ីដាក់ទុនថ្មីៗមានទាំងអ្នកស្រុក មានទាំងខ្មែរយើងមកពីបរទេស និងជាមួយ «ក្រុមអ្នក

សេដ្ឋកិច្ច» តែបើហៅថា «ក្រុមអ្នកសេដ្ឋកិច្ច» ដូចជាសំបើមពេក បើហៅថា «ក្រុមអ្នករកស៊ីឆក់កណ្ដៀតធ្វើមានឱ្យបានឆាប់» ទើបត្រូវជាងព្រោះអីពួកគេនិយាយភាសាបែបផ្សេងពីពួកយើង។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេនិយាយរបៀបដៀលមើលស្រាលចំពោះអ្នកធ្វើការតូចតាច ដូចជាគេនិយាយថា «ប្រញាប់ទៅម្ល៉េះ ផឹកស៊ីឆ្អែតសិនទៅ! ស្រុកឥឡូវគេមិនភ័យទេអារឿងទៅធ្វើការមិនទាន់ម៉ោងនោះ គេភ័យតែចេញវាមិនទាន់ម៉ោង»។ មានមនុស្សមួយជំពូកទៀត ខ្ញុំស្គាល់ច្បាស់ណាស់ កាលពីប៉ុន្មានឆ្នាំមុនៗរកតែស្រាសផឹកមិនបានផង តែឥឡូវជាមួយសេដ្ឋកិច្ចទីផ្សារទើបតែបើកចំហរ គេក្លាយជាអភិជនឥតត្រកូល ទំយើខ្លួន គេនិយាយថា «ផឹងស្រាថោកៗចេះតែឈឺពោះ»។ នៅក្នុងផ្ទះរបស់គេ កន្លែងដ៏ស្អាតសំរាប់ទទួលភ្ញៀវគេមិនរៀបចំតាំងសៀវភៅដើម្បីបង្ហាញពីការរៀនសូត្ររបស់ខ្លួន និងកូនចៅរបស់គេទេ គេតាំងបង្ហាញពីកែវស្រា ដបស្រាថ្លៃៗដែលគេទិញពីបរទេស។ វារឹតតែគួរឱ្យអៀនខ្មាសទៅទៀតនោះ អ្នកខ្លះខ្ញុំបានជួបនៅឯបរទេស គឺបើកឡានតាក់ស៊ី លក់គុយទាវ នំប៉ុង មកដល់ស្រុកពីកាលណាហ្ន៎ ស្រាប់តែស្រែកឱ្យគេហៅ «ឯកឧត្ដម» និងមានបួកពារដូចជាគិតថា នៅស្រុកខ្មែរអ្នកដែលនៅសល់ពីស្លាប់សុទ្ធតែពួកល្ងង់។ ប៉ុន្តែណ្ហើយ! ខ្ជិលគិត យើងធ្វើមិនដូចគេទេ។

ខ្ញុំបានមកដល់ផ្ទះព្រលប់ណាស់ទៅហើយ។ អ្វីដែលខ្ញុំចងចាំ គឺសំដីគ្រប់ម៉ាត់របស់ស៊ីផាន់ ដែលនៅតែធ្វើឱ្យខ្ញុំអៀនខ្លួន នឹងខ្មាសអំពើលោភៈរបស់ខ្លួន។ ខ្ញុំទន់ខ្លួនល្វើយអស់កម្លាំងរលីង មិនមែនត្រឹមតែអស់កម្លាំងកាយទេ តែកម្លាំងចិត្តក៏ទន់ខ្សោយដែរ។ យប់នោះដាច់ភ្លើងថែមទៀត ខ្ញុំក៏ទាញគ្រែមកដេកខាងក្រៅ។ ព្រលឹមឡើងទើបដឹងថា ទទឹកជោកខ្លួនព្រោះយប់មិញភ្លៀងធំ។ ខ្ញុំបន្ទោសខ្លួនឯងមិនគួរប្រឹងចំកួតស្អី រហូតល្វីល្វើម្នាក់ឯង មិនមើលខ្យល់បង្វិលទិស មិនបានត្រៀមមុនដឹងថានឹងមានភ្លៀង...៕